**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jul-2011, 13:23
CMS/CFO: Kauv Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ: **សាធារណៈ/Public**
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត**

**និង**

**សំណើសុំឲ្យមានសវនាការផ្ទាល់មាត់**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបំរុង យូរ ឧត្តរា
ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**
**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“សហមេធាវីការពារក្តី”) សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (“សំណើ”)[១]។ សំណើនេះគួរត្រូវបានច្រានចោល ពីព្រោះវាជាអញ្ញត្រកម្មមួយដែលធ្វើឡើងមិនទាន់ពេលវេលា ក្នុងការឆ្លើយតបទៅនឹងសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចថាបទរំលោភសេពសន្ថវៈមិនត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក ឡើយ[២]។ មួយវិញទៀត សំណើនេះគួរត្រូវបានបដិសេធចោលដោយសារកង្វះអង្គសេចក្តី។ អំណះអំណាងរបស់ ក.ស.ព ទាំងអស់ត្រូវបានធ្វើឡើងរួចហើយ នៅចំពោះមុខអង្គបុរេជំនុំជម្រះ[៣]។ សំណើនេះខកខានមិនបានបង្ហាញនូវកំហុសឆ្គងណាមួយដែលគេអាចវិនិច្ឆ័យបាននៅក្នុងសាលដីការបស់អង្គបុរេជំនុំជម្រះដែលថា បទរំលោភសេពសន្ថវៈពុំមែនត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក ដែលតម្រូវឱ្យមានការកែប្រែពីសំណាក់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ សហមេធាវីការពារក្តីយោងទៅលើសារណាមុនៗទាំងអស់ ដែលពាក់ព័ន្ធនឹងភាពអាចទទួលយកបាន និងអង្គសេចក្តីនៃសំណើនេះ[៤]។ សហមេធាវីការពារក្តីសូមស្នើសុំឱ្យមានការរៀបចំសវនាការផ្ទាល់មាត់ជាសាធារណៈមួយផងដែរ។

## I. សាវតារ

១. នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ សហមេធាវីការពារក្តីបានដាក់ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅ អ.វ.ត.ក

---

[១] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គបុរេជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសា E99។

[២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០០ ដល់៣១៣។

[៣] *សូមមើល* ឧបសម្ព័ន្ធ ១ ដែលរៀបរាប់ទង្វឹករណ៍របស់ ក.ស.ព នៅក្នុងបែបបទដែនការ ដែលបង្ហាញថាបញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំងអស់នេះត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅពេលណាខ្លះ។

[៤] *សូមមើល* សាវតារ។

("ញត្តិ")[៥] រួមជាមួយនឹងឧបសម្ព័ន្ធគាំទ្រមួយ[៦]។ ញត្តិបានស្នើសុំឲ្យកម្រិតនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ អ.វ.ត.ក ត្រឹមនិយមន័យរបស់ឧក្រិដ្ឋកម្មដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងជាពិសេសបានលើកឡើងថា បទរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[៧]។ ក.ស.ព មិនបានឆ្លើយតបទៅនឹងញត្តិនោះទេ រីឯ ក.ស.ច.ស ក៏មិនបានធ្វើការសម្រេចលើញត្តិនោះដែរ។

២. នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងការអង្កេតបន្ថែម[៨]។ សហមេធាវីការពារក្តីលើកឡើងម្តងទៀតអំពីគោលជំហររបស់ខ្លួនថា ការរំលោភផ្លូវភេទ "*មិន*

---

[៥] ញត្តិផ្សេងទៀតរបស់លោក អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អ.វ.ត.ក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D378/2។

[៦] ញត្តិផ្សេងទៀតរបស់ អៀង សារី ស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅ អ.វ.ត.ក ឧបសម្ព័ន្ធៈ សេចក្តីសង្ខេបនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការវិវឌ្ឍន៍នៃឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D378/2.2។

[៧] ញត្តិបានពន្យល់ថា ការរំលោភផ្លូវភេទ "*ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់* មិនត្រូវបានរាយបញ្ជីនៅក្នុង (ក) ធម្មនុញ្ញតុលាការយោធាអន្តរជាតិ (ខ) ធម្មនុញ្ញឆ្នាំ ១៩៤៦ របស់តុលាការយោធា អន្តរជាតិសម្រាប់ចុងបូព៌ា (គ) គោលការណ៍Nuremberg (ឃ) សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៤ នៃបទល្មើសនានាប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សជាតិ ឬ (ង) អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីភាពមិនអាចអនុវត្តបាននៃអាជ្ញាយុកាលចំពោះ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ការមិនចែងពីអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិនៅក្នុងលិខិតុបករណ៍ទាំងអស់នេះ បង្ហាញថា អំពើនេះមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូច ដែលបានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឡើយ"។ ញត្តិ កថាខណ្ឌ ១៦។ លើសពីនេះទៀត ញត្តិបានលើកឡើង "ថា ការរាប់បញ្ចូលអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនមានលក្ខណៈដាច់ខាតនោះទេ។ តុលាការសម្ព័ន្ធមិត្ត និងតុលាការ អាល្លឺម៉ង់ដែលអនុវត្តច្បាប់នេះ គឺជា "តុលាការជាតិដែលជាធម្មតាប្រើប្រាស់ច្បាប់ជាតិ (ច្បាប់ក្នុងស្រុក) ដែលការពិតនោះ បានបញ្ចូលនូវបទប្បញ្ញត្តិនានាដែលមានដើមកំណើតចេញមកពីអាជ្ញាធរដែលត្រួតត្រាប្រទេសនោះ"។ ញត្តិ ជើងទំព័រ លេខ ៥២។

[៨] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងការអង្កេតបន្ថែម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/1.3។

*មែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចដែលបានរៀបរាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងរយៈកាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩*" នោះទេ[៩]។

៣. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ក.ស.ច.ស បានដាក់ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២[១០]។ ដីកាដំណោះស្រាយបានចោទប្រកាន់លោក អៀង សារី ពីបទ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាពិសេស ...(ឆ) ការរំលោភលើផ្លូវភេទ... ដែលអាចផ្តន្ទាទោសដោយមាត្រា ៥... នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក"[១១]។ លើសពីនេះទៀត ដីកាដំណោះស្រាយបានលើកឡើងថា "និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺការប្រព្រឹត្តអំពើមួយ ឬច្រើនក្នុងចំណោមអំពើទាំងឡាយខាងក្រោម ដែលជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលៈ...អំពើរំលោភសេពសន្ថវៈ ..."[១២]។

៤. នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១០ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[១៣]។ មេធាវីការពារក្តីបានលើកឡើងថា ក.ស.ច.ស បានភ័ន្តច្រឡំដោយយល់ឃើញថា អំពើរំលោភសេពសន្ថវៈគឺជាអំពើបង្កជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[១៤] និងបានធ្វើការអះអាងជាថ្មីម្តងទៀតអំពីហេតុផលរបស់ខ្លួនសម្រាប់ការលើកឡើងនេះ[១៥]។

៥. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ ក.ស.ព បានដាក់ចម្លើយតបរួមរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយលើកឡើងថា "ដូចដែលត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* រួចមកហើយ គឺថា

---

[៩] ដូចខាងលើ កថាខណ្ឌ ៥៣។

[១០] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយ")។

[១១] ដូចខាងលើ កថាខណ្ឌ ១៦១៣។

[១២] ដូចខាងលើ កថាខណ្ឌ ១៣៦០។

[១៣] បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១០ ឯកសារ D427/1/6។

[១៤] ដូចខាងលើ កថាខណ្ឌ ២១៨។

[១៥] ដូចខាងលើ កថាខណ្ឌ ១៨៨ ដល់១៨៩។

ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិយ៉ាងច្បាស់ និងជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩"[១៦]។ សហមេធាវីការពារក្តីបានឆ្លើយតបទៅនឹងទឡ្ហីករណ៍នេះ នៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០[១៧]។

៦. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលក្នុងនោះ អង្គបុរេជំនុំជម្រះបានអនុញ្ញាតតាមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយចំនួនរបស់មេធាវីការពារក្តី:

> មូលដ្ឋានបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាពដែលសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"[១៨]។

៧. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង។ កាលបរិច្ឆេទនេះបានចាប់ផ្តើមរាប់រយៈពេលសម្រាប់ការដាក់អញ្ញត្រកម្ម ដែលធ្វើឲ្យកាលបរិច្ឆេទផុតកំណត់

---

[១៦] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០១០ ឯកសារ D427/3/6 ផ្នែក I.២ កថាខណ្ឌ ១៩០។

[១៧] សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារ D427/1/23 ("សារណាឆ្លើយតប") កថាខណ្ឌ ៩៨។

[១៨] នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសំអាងហេតុរបស់ខ្លួនសម្រាប់សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ")។

ដំបូងសម្រាប់ការដាក់អញ្ញត្រកម្មនេះ គឺថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[១៩]។ ក.ស.ព បានដាក់អញ្ញត្រកម្មតាមកាលបរិច្ឆេទនោះ[២០]។

## II. ចម្លើយតបលើបញ្ហានីតិវិធី: សំណើធ្វើឡើងមិនទាន់ពេលវេលា និងគួរត្រូវបានច្រានចោល

៨. អង្គជំនុំជម្រះសាលាដំបូងកំពុងត្រូវបានស្នើសុំ ឱ្យបដិសេធសាលដីកាផ្នែកយុត្តាធិការរបស់អង្គបុរេជំនុំជម្រះដែលសម្រេចថា ការរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់ នៅ អ.វ.ត.ក នោះទេ[២១]។ សំណើសុំនេះគឺជាអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងមិនចាំបាច់យកចិត្តទុកដាក់លើសំណើរបស់ ក.ស.ព សុំឱ្យកំណត់បទចោទនៃអង្គហេតុជាថ្មីឡើងវិញ ដោយខ្លួនមិនទាន់សម្រេចលើបញ្ហា ថាតើការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់ ពិតជាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ជាមុនសិននោះទេ។ បញ្ហានេះគឺជាបញ្ហាផ្នែកយុត្តាធិការ។ បញ្ហានេះត្រូវបានលើកឡើងថាជាបណ្តឹងជំទាស់ផ្នែកយុត្តាធិការ តាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង នៅដំណាក់កាលមុនសវនាការ ហើយអង្គបុរេជំនុំជម្រះបានយល់ឃើញថា សំណើនេះអាចទទួលយកបាន។ អង្គបុរេជំនុំជម្រះបានលើកឡើងថាខ្លួន "សង្កេតឃើញថា នៅក្នុងមូលដ្ឋានរងមួយចំនួននៃមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ... រួមមាន... កថាខណ្ឌរង ១៤ ("ទឡ្ហីករណ៍ស្តីពីការរំលោភផ្លូវភេទ") ... សហមេធាវីការពារក្តី លើកឡើងអំពី <u>អត្ថិភាពផ្លូវច្បាប់</u> ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៃប្រភេទមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែល<u>តំណាងឱ្យទឡ្ហីករណ៍ដែលជាខ្លឹមសារនៃការវិនិច្ឆ័យ ស្របតាមគោលការណ៍</u>

---

[១៩] *សូមមើល* ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9។

[២០] *សូមមើល* ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មិនដាក់បញ្ចូលលក្ខខណ្ឌកំណត់អំពីចំណងទាក់ទងនៃជម្លោះប្រដាប់អាវុធ ទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសំណើសុំបើកសវនាការដេញដោលមួយ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ សម្រាប់សារតារនីតិវិធី ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃសំណើ។

[២១] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣០០ ដល់៣១៣។

នីត្យានុកូលភាព ដូចនេះហើយ តំណាងឱ្យបណ្តឹងជំទាស់ផ្នែកយុត្តាធិការ ដែលអាចទទួលយកបាន”[២២]។

៩. បណ្តឹងជំទាស់ផ្នែកយុត្តាធិការនៅដំណាក់កាលជំនុំជម្រះ ត្រូវបានរំពឹងទុកដោយវិធានផ្ទៃក្នុង ដែលត្រូវបានអនុម័តជាពិសេសសម្រាប់ អ.វ.ត.ក[២៣] និងមានអាទិភាពលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[២៤]។ វិធានផ្ទៃក្នុង ៨៩(១) ចែងថា អញ្ញត្រកម្មទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង “ត្រូវលើកឡើងយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ”។ ដោយសារតែដីកាដំណោះស្រាយ បានចូលជាស្ថាពរនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់អញ្ញត្រកម្មទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលសម្រេចថាការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់ គឺថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[២៥]។

១០. ក.ស.ព មិនបានដាក់អញ្ញត្រកម្មតាមវិធានផ្ទៃក្នុង ៨៩ នោះទេ។ *ពេលនេះ* ក.ស.ព ធ្វើការជំទាស់ទៅនឹងការកំណត់ព្រំដែនយុត្តាធិការ ប្រហែលរយៈពេលបួនខែ ក្រោយកាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់អញ្ញត្រកម្ម អនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង។ អាចដោយសារនេះយុទ្ធវិធី ឬដោយផ្អែកតាមកង្វះការយកចិត្តទុកដាក់របស់ខ្លួន ដោយបានសម្រេចមិនដាក់អញ្ញត្រកម្ម *ពេលនេះ* ក.ស.ព ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង “កំណត់បទចោទឡើងវិញទាក់ទិននឹងអង្គហេតុនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយកំណត់នូវអំពើរំលោភសេពសន្ថវៈ ជាបទ

---

[២២] ដូចខាងលើ កថាខណ្ឌ ៨៤ (សេចក្តីបញ្ជាក់បន្ថែម)។

[២៣] វិធាននានាត្រូវបានកែប្រែដើម្បីបំព្រួញរយៈពេលសម្រាប់លើកឡើងនូវអញ្ញត្រកម្ម-ពេលនេះ បញ្ហាទាំងអស់នេះត្រូវបានដោះស្រាយឱ្យបានល្អមុនពេលជំនុំជម្រះក្តី។ តាមវិធីនេះ អ.វ.ត.ក មានលក្ខណៈស្រដៀងគ្នាទៅនឹង តុលាការ *មិនអចិន្ត្រៃយ៍* ដែលតុលាការទាំងអស់តម្រូវឱ្យមានបញ្ហាយុត្តាធិការ-ដូចជា យុត្តាធិការរបស់តុលាការលើបទឧក្រិដ្ឋ មួយចំនួន និងទម្រង់នៃការទទួលខុសត្រូវ - ដែលត្រូវលើកឡើងនៅក្នុងរយៈពេល ជាក់លាក់មួយឱ្យបានល្អមុនពេលចាប់ផ្តើមជំនុំជម្រះក្តី។ *សូមមើល* វិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY វិធាន ៧២(ក)។ វិធាននីតិវិធី និងភ័ស្តុតាងរបស់ តុលាការ ICTR វិធាន ៧២(ក)។

[២៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។

[២៥] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9។

រំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"[២៦]។ ក.ស.ព ធ្វើសំណើនេះ ជាសំណើកំណត់បទចោទសាជាថ្មី អនុលោមតាមវិធាន៩៨ នៃវិធានផ្ទៃក្នុង[២៧]។ ការកំណត់បទចោទសាជាថ្មីតាមវិធាន៩៨ នៃវិធានផ្ទៃក្នុង ពុំមែនជាមធ្យោបាយដើម្បីចៀសឲ្យផុតពីវិធាន៨៩ នោះទេ។

១១. បញ្ហានេះត្រូវបានលើកឡើងទាន់ពេលវេលា និងត្រូវបានជជែកវែកញែកគ្នាយ៉ាងខ្លាំង នៅដំណាក់កាលបុរេជំនុំជម្រះ[២៨]។ អនុលោមតាមវិធានផ្ទៃក្នុង ៧៤(៣)(ក) អង្គបុរេជំនុំជម្រះបានកំណត់អង្គច្បាប់ចំពោះបណ្តឹងផ្នែកយុត្តាធិការ[២៩]។ ក.ស.ព មិនបានធ្វើការជំទាស់ទេ។ ដូច្នេះ សំណើនេះគួរត្រូវបានបដិសេធចោល។

## III. ការឆ្លើយតបលើបញ្ហាអង្គសេចក្តី : បទរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់ នៅ អ.វ.ត.ក នោះទេ

### ក. បទរំលោភសេពសន្ថវៈពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ

១២. អង្គបុរេជំនុំជម្រះបានយល់ឃើញថា ក្រម Lieber Code ឆ្នាំ ១៨៦៣ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩០៧ (ដែលបានចែងរួមជាមួយ Martens clause ចាប់ពីបុព្វកថា ដល់អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៨៩៩ (II)) គណៈកម្មការស្តីពីការទទួលខុសត្រូវអ្នកបង្កសង្គ្រាម និងការអនុវត្តទោស ឆ្នាំ ១៩១៩ អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងពិធីសារ I និង II មិនបានបង្ហាញគ្រប់គ្រាន់អំពីការចាត់ទុកជាបទឧក្រិដ្ឋតាមទំនៀមទម្លាប់ចំពោះការរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដើម្បីរកឲ្យឃើញថា នៅត្រឹមឆ្នាំ១៩៧៥ ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៣០]។ ក.ស.ព ខកខានមិនបានលើកឡើងពីការយល់

---

[២៦] សំណើ កថាខណ្ឌ ១។

[២៧] ដូចខាងលើ។

[២៨] *សូមមើល* សារណា។

[២៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៧ ដល់៣៧២។

[៣០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៧ ដល់៣៧១។ *សូមមើលផងដែរ* Rhonda Copelon *ឧក្រិដ្ឋកម្មទាក់ទងនឹងយេនឌ័រ ថាជាឧក្រិដ្ឋកម្មសង្គ្រាម: ការបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីភេទ*

ឃើញនេះទេ នៅពេល ក.ស.ព បានធ្វើការអះអាងថា លិខិតុបករណ៍ទាំងអស់នេះ គឺជាការឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ឡើងបន្តិចម្តងៗ នៃការបញ្ចូលបទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ដោយស្វ័យប្រវត្តិ" ចាប់តាំងពីសតវត្សរ៍ទី ១៩ មកម្ល៉េះ[៣១]។ លិខិតុបករណ៍មនុស្សធម៌អន្តរជាតិមិនអាចដាក់បញ្ចូលទាំងស្រុង តាមសទិសភាព ដើម្បីកំណត់ ថាតើការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬយ៉ាងណាឡើយ[៣២]។

១៣. អង្គបុរេជំនុំជម្រះបានយល់ឃើញថា ទោះបីជាការរំលោភសេពសន្ថវៈត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់ នៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងក៏ដោយ អង្គបុរេជំនុំជម្រះមិនអាចរកឧទាហរណ៍នៃការផ្តន្ទាទោសលើការរំលោភសេពសន្ថវៈអនុលោមតាមច្បាប់នេះបានដែរ[៣៣]។ ក.ស.ព បានផ្អែកលើការកំណត់ការរំលោភសេពសន្ថវៈជា

---

*ទៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ* MCGILL L.J., ខែ វិច្ឆិកា ឆ្នាំ ២០០០ ("Copelon")៖ "ក្រម Leiber [sic] Code ដែលត្រូវបានព្រាងដើម្បីថែងពីកងទ័ពសហព័ន្ធនៅក្នុងអំឡុងពេលសង្គ្រាមអាមេរិក បានកំណត់ការរំលោភផ្លូវភេទថាជា បទល្មើសធំមួយ។ ផ្សេងពីនេះ ប្រសិនបើត្រូវបានដាក់ទោស ថាការរំលោភផ្លូវភេទស្ថិតនៅក្នុងអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩០៧ និងអនុសញ្ញាទីក្រុងហ្សឺណែវ វាមិនច្បាស់ជាបែបនេះទេ ដែលត្រូវបានចាត់ជាប្រភេទបទល្មើសប្រឆាំងនឹង "កិត្តិយស និងសិទ្ធិរបស់ក្រុមគ្រួសារ" ឬថាជា "អំពើឃោរឃៅប្រឆាំងនឹងសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន" ឬក៏ "ការប្រព្រឹត្ត បំបាក់មុខ និង ធ្វើឲ្យអាប់យស"។ អនុសញ្ញាទីក្រុងហ្សឺណែវទីបួន បានអំពាវនាវរក "ការការពារប្រឆាំងនឹងការរំលោភ ផ្លូវភេទថាជា ... ការវាយប្រហារលើកិត្តិយសរបស់ពួកគេ" ប៉ុន្តែការរំលោភផ្លូវភេទមិនត្រូវបានចាត់ទុកថាជាអំពើហិង្សា នោះទេ ហេតុដូច្នេះហើយមិនត្រូវបានរៀបរាប់ឈ្មោះនៅក្នុងបញ្ជីនៃ "ការបំពារបំពានធ្ងន់ធ្ងរ" ដែលត្រូវជាប់កាតព្វកិច្ចជាសកលដែលត្រូវកាត់ទោសនោះឡើយ។ នៅឆ្នាំ ១៩៧៧ ពិធីសារទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ បានលើកឡើងពី "ការរំលោភផ្លូវភេទ ការធ្វើពេស្យាកម្មដោយបង្ខំ និងទម្រង់ផ្សេងទៀតនៃការបៀតបៀនកេរ្តិ៍ខ្មាស" ត្រឹមតែជា "ការប្រព្រឹត្ត បំបាក់មុខ ឬធ្វើឲ្យអាប់យស" ប៉ុណ្ណោះ ដែលជាការកំណត់មួយដែលជាការគាំទ្រថែមទៀតដល់សារៈសំខាន់បន្ទាប់បន្សំ ក៏ដូចជាភាពអៀនខ្មាស និងស្លាកស្នាមទុយ៌សរបស់ស្ត្រីដែលជាជនរងគ្រោះ។ បទល្មើសគឺធ្វើឡើងប្រឆាំងនឹងសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់មនុស្សប្រុស ឬកិត្តិយសជាតិ ឬកិត្តិយសរបស់ជាតិពន្ធុ។ នៅក្នុងសេណារីយ៉ូនេះ ស្ត្រីគឺជាកម្មវត្ថុនៃការវាយប្រហារភាពអៀនខ្មាស ជាកម្មសិទ្ធិ ឬកម្មវត្ថុរបស់ការវាយប្រហារផ្សេងទៀត ដែលប្រហែលជាត្រូវការការការពារ ប៉ុន្តែមិនមែនជាប្រធានបទនៃសិទ្ធិទាំងឡាយនោះទេ"។ (សម្រង់ផ្នែកក្នុងត្រូវបានលុបចោល)។

[៣១] សំណើ កថាខណ្ឌ ១២។

[៣២] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៨៦ ដល់១៨៧។

[៣៣] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៨។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[៣៤]។ តុលាការរបស់ប្រទេសសម្ព័ន្ធមិត្ត និងតុលាការអាល្លឺម៉ង់ដែលអនុវត្តច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ត្រូវបានចាត់ទុកថាជា "តុលាការក្នុងស្រុកដែលគ្រប់គ្រងច្បាប់ក្នុងស្រុក (ច្បាប់ផ្ទៃក្នុងប្រទេស) ជាអាទិ"[៣៥] និង "នៅក្នុងលទ្ធផលផ្ទាល់នៃសង្គ្រាមលោកលើកទី២ និយមន័យ [របស់តុលាការយោធាអន្តរជាតិ] ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានយល់ឃើញថា ជាសេចក្តីថ្លែងការណ៍អំពីច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់"[៣៦]។ គោលការណ៍Nuremberg (ដែលមិនបានកំណត់ការរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) បានឆ្លុះបញ្ចាំងពីការយល់ឃើញនេះ[៣៧]។

១៤. ក.ស.ព ទទួលស្គាល់ថា ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិនៅNuremberg និងនៅតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា មិនបានកំណត់ការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ[៣៨]។ សារៈសំខាន់នៃការមិនបូកបញ្ចូលទាំងអស់នេះ រួមជាមួយនឹងការមិនបូកបញ្ចូលការរំលោភសេពសន្ថវៈទៅក្នុងគោលការណ៍Nuremberg មិនអាចត្រូវបានបន្ធូរបន្ថយទេ។ អំពើសាហាវយង់ឃ្នងនានា នៃអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តលើក្មេងស្រី និងស្ត្រីវ័យក្មេងរាប់ពាន់នាក់ ដែលមិនមែនជាជនជាតិជប៉ុនមកពីប្រទេសជប៉ុន ដែលបានកាន់កាប់ដែនដីជាច្រើនក្នុង

---

[៣៤] សំណើ កថាខណ្ឌ ១៤ ដល់ ១៥។

[៣៥] Egon Schwelb *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ 23 B.Y.B. INT'L L. 178, 218-19 (ឆ្នាំ ១៩៤៦)* ។ *សូមមើលផងដែរ Attila Bogdan ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៅក្នុងការអនុវត្ត "សហឧក្រិដ្ឋកម្មរួម" នៅក្នុងច្បាប់យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនអចិន្ត្រៃយ៍សម្រាប់អតីតយូហ្គោស្លាវី* 6 INT'L CRIM. L. REV. 63, 110 (ឆ្នាំ ២០០៦)។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង "មិនអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់អន្តរជាតិបានទេ ពីព្រោះច្បាប់នេះត្រូវបានអនុម័តដោយអាជ្ញាធរតាក់តែងច្បាប់លើប្រទេសអាល្លឺម៉ង់ (ក្រុមប្រឹក្សាគ្រប់គ្រងសម្ព័ន្ធមិត្ត)។ ជាលទ្ធផលសាលក្រមដែលបានចេញយោងតាម ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង <u>មិនបង្កើតបានជាអត្ថិភាព អន្តរជាតិដែលមានសុពលភាពនោះទេ</u> រីឯ "គោលការណ៍ដែលចូលរួមនៃការទទួលខុសត្រូវព្រហ្មទណ្ឌ" ដែលត្រូវបានជូនដំណឹងនៅពេលជំនុំជម្រះក្តីទាំងអស់នេះ "ពុំមានសុពលភាពនៅពេលក្រោយមកទៀតទេនៅក្នុងច្បាប់ព្រហ្មទណ្ឌ អន្តរជាតិនោះ"។

[៣៦] *សូមមើល* Stuart Ford *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា: តើជាការទាក់ទងនឹងជម្លោះប្រដាប់អាវុធដែលចាំបាច់ដែរឬទេ?* 24 UCLA PAC. BASIN L.J. 125, 148, 151 (ឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧)។

[៣៧] គោលការណ៍Nuremberg គោលការណ៍ VI(គ)។

[៣៨] សំណើ កថាខណ្ឌ ១៥។

អំឡុងសង្គ្រាមលោកលើកទី២ មិនត្រូវបានតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា "យកចិត្តទុកដាក់នោះទេ"[៣៩]។ ការបដិសេធមិនចោទប្រកាន់បទឧក្រិដ្ឋទាំងអស់នេះ ក្រោយសង្គ្រាមលោកលើកទី២ បានធ្វើឲ្យអ្នកធ្វើអត្ថាធិប្បាយកត់សម្គាល់ឃើញថា "មុនទសវត្សរ៍ឆ្នាំ ១៩៩០ អំពើហិង្សាផ្លូវភេទ នៅក្នុងពេលសង្គ្រាម ភាគច្រើនមិនត្រូវបានគេមើលឃើញទេ ដោយកម្រមានករណីលើកលែងណាស់។ ប្រសិនបើមិនត្រូវបានគេមើលឃើញទេនោះ មានន័យថាគេទុកវាជារឿងមិនសំខាន់។ តែប្រសិនបើត្រូវបានគេទុកជារឿងសំខាន់វិញនោះ វាត្រូវបានគេយល់ឃើញថា វាគ្រាន់តែជាបញ្ហាផ្ទាល់ខ្លួនប៉ុណ្ណោះ ឬត្រូវបានគេធ្វើយុត្តិកម្មថា វាជាអនុផលនៃសង្គ្រាមដែលចៀសមិនរួច និងជាការឲ្យរង្វាន់ដែលចាំបាច់សម្រាប់អ្នកធ្វើសង្គ្រាម"[៤០]។ បញ្ហានេះបានលើកឡើងថែមទៀតថា ត្រឹមឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ឡើងៗថា ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។

១៥. ក.ស.ព អះអាងថា ការចាត់ទុកបទរំលោភសេពសន្ថវៈ ជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី"តុលាការ ICTY" និងទាំងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា "តុលាការ ICTR" "បានផ្អែកលើមូលដ្ឋាននៃការយល់ដឹងអំពីច្បាប់តាមទម្លាប់អន្តរជាតិ *នៅមុនពេល* មានការអនុម័តលក្ខន្តិកៈទាំងនោះ"[៤១]។ ក.ស.ព ពឹងផ្អែកទៅលើកថាខណ្ឌ៣៤ នៃរបាយការណ៍របស់លោកអគ្គលេខាធិការ អនុលោមទៅតាមកថាខណ្ឌ២ នៃសេចក្ដីសម្រេចចិត្តលេខ៨០៨ របស់ក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៣ គាំទ្រដល់ការអះអាងនេះ("របាយការណ៍")[៤២]។ កថាខណ្ឌ៣៤ នៃរបាយការណ៍នេះចែងថា "ការអនុវត្តនូវគោលការណ៍ *មិនមានជាបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* តម្រូវថា តុលាការអន្តរជាតិគួរយកមកអនុវត្តនូវវិធាននៃច្បាប់តាមទំនៀមទម្លាប់អន្តរជាតិ ដែលស្ថិតក្នុងផ្នែកហួសពីវិមតិសង្ស័យ នៃច្បាប់ទំនៀម

---

[៣៩] Copelon ត្រង់ ២១៩ ដល់ ២២១។

[៤០] ដូចខាងលើ។

[៤១] សំណើ កថាខណ្ឌ១៦។

[៤២] *ដូចជើងទំព័រខាងលើ* លេខ៣១ អំពីរបាយការណ៍របស់លោកអគ្គលេខាធិការ អនុលោមទៅតាមកថាខណ្ឌ២នៃសេចក្ដីសម្រេចចិត្តលេខ៨០៨នៃក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី៣ ខែ ឧសភា ឆ្នាំ ១៩៩៣ (S/25704) កថាខណ្ឌ៣៤។

ទម្លាប់អន្តរជាតិ"[៤៣]។ នេះ ពុំមានន័យថា បទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានកំណត់ក្នុងលក្ខន្តិកៈ តុលាការ ICTY ស្ថិតក្នុងផ្នែក "ហួសពីវិមតិសង្ស័យ" នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនពេល (ឬថែមទាំងនៅពេលដែល) ប្រកាសឲ្យប្រើប្រាស់ច្បាប់នេះទៀតផង។ ផ្ទុយទៅវិញ វាមានន័យថា តុលាការ ICTY ត្រូវបន្តដំណើរការនីតិវិធីដោយការប្រុងប្រយ័ត្ន ដើម្បីធានាថា មានតែវិធានទាំងនោះប៉ុណ្ណោះ ដែលតាមពិតជាផ្នែក "ហួសពីវិមតិសង្ស័យ"នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបាន*យកមកអនុវត្ត* នៅតុលាការនេះ។ ចំណុចខាងលើត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងកថាខណ្ឌ៣៥ នៃរបាយការណ៍នេះ ដោយបំភ្លឺថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានលក្ខណៈ "ហួសពីវិមតិសង្ស័យ" ដែលអាចយកមកអនុវត្តបានក្នុងជម្លោះប្រដាប់អាវុធ មានចែងក្នុង៖ **ក.** អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ **ខ.** អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩០៧ (IV) **ឃ.** អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ១៩៤៩ និង **ង.** ធម្មនុញ្ញ ឆ្នាំ១៩៤៥ នៃតុលាការយោធាអន្តរជាតិ។ ដោយពិចារណាថា បទរំលោភសេពសន្ថវៈដែលពុំត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងចំណោមលិខិតុបករណ៍ទាំងនេះនោះ ក.ស.ព មានការភ័ន្តច្រឡំដោយពឹងផ្អែកទៅលើរបាយការណ៍នេះ។

១៦. ក.ស.ព សន្និដ្ឋានថា វាជាការត្រឹមត្រូវមួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញអនុវត្តតាមយុត្តិសាស្ត្រដែលត្រូវបានគេបង្កើតឡើងសម្រាប់បញ្ហានេះនៅតុលាការ ICTY, តុលាការ ICTR និងតុលាការ SCSL[៤៤]។ ក.ស.ព បន្ថែមថា ការបកស្រាយបំភ្លឺបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "វាត្រូវតែបានកើតឡើងនៅពេលភ្លាមៗ បន្ទាប់ពីការងើបឡើងពីសង្គ្រាមលោកលើកទី២ ដោយសារតែវាពុំមានការអភិវឌ្ឍជាដុំកំភួននូវទម្លាប់ ឬយុត្តិសាស្ត្រ ដែលទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈ នៅក្នុងរវាងឆ្នាំ ១៩៤៥ ដល់ឆ្នាំ ១៩៩៣"[៤៥]។ ទីមួយ តុលាការ ICTY, តុលាការ ICTR ឬ តុលាការ SCSL នៅពុំទាន់បានស្នើសុំឲ្យសម្រេចលើឋានៈជាទំនៀមទម្លាប់នៃបទរំលោភសេពសន្ថវៈថា ត្រូវផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅឡើយក្នុងចន្លោះឆ្នាំ១៩៧៥-៧៩។ ទីពីរ ការអះអាងរបស់ ក.ស.ព ដែលថា ពុំទាន់មាន

---

[៤៣] បន្ថែមការគូសបញ្ជាក់ដែលមានដិតបន្ទាត់ពីក្រោម។

[៤៤] សំណើ កថាខណ្ឌ១៨។

[៤៥] *ដូចជើងទំព័រខាងលើ។*

ការអភិវឌ្ឍផ្នែកសម្ភារៈនៅឡើយ នៅចន្លោះឆ្នាំ ១៩៤៥ និងឆ្នាំ ១៩៩៣ គឺពុំមានអង្គសេចក្តីអ្វីឡើយ។ ក.ស.ព អើពើនឹងការលុបចោលបទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចេញពី គោលការណ៍តុលាការ Nuremberg ។ ក.ស.ព ក៏ខកខានមិនទទួលយក ក្នុងបរិបទនៃការអភិវឌ្ឍនៃ ការដាក់បញ្ចូលបញ្ញាយេនឌ័រក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បន្ទាប់ពីចុងសង្គ្រាមត្រជាក់[៤៦] សន្និសីទ ទីក្រុងវីយ៉ែន ឆ្នាំ ១៩៩៣ ស្តីពីសិទ្ធិមនុស្ស និងជាលទ្ធផលបណ្តាលឲ្យកើតមានសេចក្តីប្រកាស ទីក្រុងវីយ៉ែន និងកម្មវិធីសកម្មភាព[៤៧]។

---

[៤៦] *សូមមើល* Copelon។ សម្រាប់ការបំភ្លឺបន្ថែមអំពីផលប៉ះពាល់នៃចុងសង្គ្រាមត្រជាក់លើការបង្កើតច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងនិយាមសិទ្ធិមនុស្សអន្តរជាតិដែលមានលក្ខណៈទូទៅជាងនេះ *សូមមើល e.g.*, Randall Lesaffer, *The End of the Cold War: An Epochal Event in the History of International Law?*, Tilburg University និង Catholic University of Leuven *អាចរកមើលបាននៅ* http://papers.ssrn.com/sol3/papers.cfm?abstract_id=1663871។ *ក៏សូមមើល* W. Michael Reisman, *International Law after the Cold War*, 84 AM. J. INT'L L. 859, 861 (1990).

[៤៧] "នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៣ តំណាងមកពីរដ្ឋ១៧១បានអនុម័តជាឯកច្ឆន្ទ នូវសេចក្តីប្រកាសទីក្រុងវីយ៉ែន និងកម្មវិធីសកម្មភាពនៃសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស ដូច្នេះបានបញ្ចប់ដោយជោគជ័យនូវសន្និសីទពិភពលោករយៈពេលពីរសប្តាហ៍ និងបង្ហាញដល់សហគមន៍អន្តរជាតិ នូវផែនការរួមមួយសម្រាប់ការពង្រឹងកិច្ចការពាក់ព័ន្ធនឹងសិទ្ធិមនុស្សនៅជុំវិញពិភពលោក។ សន្និសីទនេះត្រូវបានកំណត់ដោយកម្រិតដែលមិនធ្លាប់មានពីមុនមកនៃការចូលរួមដោយប្រតិភូរដ្ឋាភិបាល និងសហគមន៍សិទ្ធិមនុស្សអន្តរជាតិ។ អ្នកចូលរួមប្រមាណ៧០០០នាក់ ក្នុងនោះរួមមាន អ្នកសិក្សាស្រាវជ្រាវ អង្គការសន្ធិសញ្ញាស្ថាប័នជាតិ និងតំណាងមកពីអង្គការមិនមែនរដ្ឋាភិបាលជាង៨០០ ដែលពីរភាគបីនៃពួកគេមកពីថ្នាក់មូលដ្ឋាន បានប្រមូលផ្តុំគ្នានៅទីក្រុងវីយ៉ែន ដើម្បីពិនិត្យមើល និងទទួលបានចំណេះដឹងពីការចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក។ សេចក្តីប្រកាសទីក្រុងវីយ៉ែន និងកម្មវិធីសកម្មភាពបានកំណត់នូវកម្រិតខ្ពស់បំផុតនៃដំណើរការដ៏យូរនៃការពិនិត្យ និងជជែកពិភាក្សាលើស្ថានការណ៍បច្ចុប្បន្ននៃយន្តការសិទ្ធិមនុស្សនៅក្នុងពិភពលោក។ សន្និសីទនេះក៏បានកំណត់នូវការចាប់ផ្តើមនៃកិច្ចខិតខំប្រឹងប្រែងថ្មីៗ ក្នុងការពង្រឹង និងអនុវត្តបន្ថែមទៀតនូវអង្គនៃលិខិតុបករណ៍សិទ្ធិមនុស្ស ដែលត្រូវបានបង្កើតឡើងយ៉ាងពិបាក ដោយឈរលើមូលដ្ឋាននៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចាប់តាំងឆ្នាំ១៩៤៨មក។ សន្និសីទនេះបានបោះជំហានជាប្រវត្តិសាស្ត្រថ្មីៗ ក្នុងការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី កុមារ និងជនជាតិដើមភាគតិច"។ អត្ថបទដកស្រង់ចេញពីDPI /1394/Rev.1/HR-95-93241, ចុះខែ មេសា ឆ្នាំ ១៩៩៥ *អាចរកមើលបាននៅ* http://www.ohchr.org/EN/ABOUTUS/Pages/ViennaWC.aspx។ គួរឲ្យកត់សម្គាល់ សេចក្តីប្រកាសទីក្រុងវីយ៉ែន និងកម្មវិធីសកម្មភាពបានសង្កត់ធ្ងន់លើតម្រូវការឲ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបទរំលោភសេពសន្ថវៈជាលក្ខណៈប្រព័ន្ធ៖ <u>"ការបំពារបំពានសិទ្ធិមនុស្សរបស់នារីភេទ ក្នុងកាលៈទេសៈជម្លោះប្រដាប់អាវុធ ជាការបំពារបំពានទៅលើគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ។ ការបំពារបំពានប្រភេទនេះទាំងអស់ ក្នុងនោះរួមមានជាពិសេស ការសម្លាប់ បទរំលោភសេពសន្ថវៈជាលក្ខណៈប្រព័ន្ធ ទាសភាពផ្លូវភេទ និងការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ តម្រូវឲ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពជាពិសេសមួយ"</u>

១៧. ក.ស.ព អះអាងថា ការពឹងផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការអន្តរជាតិ បន្ទាប់ពីខែ មករា ឆ្នាំ១៩៧៩ មក ពុំបំពានទៅលើគោលការណ៍នីត្យានុកូលភាពឡើយ។ ផ្ទុយទៅវិញ "សេចក្តីសម្រេចទាំងនេះផ្តល់នូវការណែនាំបកស្រាយទាក់ទងនឹងស្ថានភាពការវិវឌ្ឍន៍ នៃឧក្រិដ្ឋកម្មមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិ"[៤៨]។ បើទោះជាសហាមេធាវីការពារក្តីឯកភាពនឹងអំណះអំណាងនេះជាគោលការណ៍ក៏ដោយ ក៏ការបញ្ជាក់ថា បទរំលោភសេពសន្ថវៈដែលបានកើតឡើង និងត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់តុលាការ *មិនអចិន្ត្រៃយ៍*នានា គឺហួសពីតួនាទីបន្ទាប់បន្សំដែលបានរំពឹងទុក សម្រាប់ការកំណត់តាមផ្លូវតុលាការទុកជាការណែនាំសម្រាប់បកស្រាយ ដូច្នេះហើយវានឹងបំពារបំពានលើគោលការណ៍នីត្យានុកូលភាព[៤៩]។

១៨. ក.ស.ព អះអាងថា ការយល់ឃើញយល់ឃើញរបស់ អ.វ.ត.ក ដែលថា បទរំលោភសេពសន្ថវៈមិនមែនជាបទឧក្រិដ្ឋដែលមានចែងច្បាស់លាស់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងឆ្នាំ១៩៧៥-៧៩ គឺមានន័យថា ការយល់ឃើញរបស់ តុលាការ*មិនអចិន្ត្រៃយ៍*នានា (ទាក់ទងនឹងបទរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ) គឺជាការខុសឆ្គង[៥០]។ ដូចបានកត់សម្គាល់ខាងលើ ចុងសង្គ្រាមត្រជាក់ បានបង្កើតនូវវេទិកានយោបាយ នៅសហគមន៍អន្តរជាតិ

---

(គូសបញ្ជាក់បន្ថែម)។ សេចក្តីប្រកាសទីក្រុងវីយែន និងកម្មវិធីសកម្មភាព ឯកសារលេខ A/CONF.157/23 ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ១៩៩៣ ផ្នែកទី II កថាខណ្ឌ៣៨។

*ក៏សូមមើល* Copelon, ទំព័រ២២០៖ "ទសវត្សរ៍ចុងក្រោយនេះ (១៩៩០-២០០០) មានលក្ខណៈជាប្រវត្តិសាស្ត្រ ដោយថា មានការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ ក្នុងការកែប្រែការថ្លែងសុន្ទរកថានៅកម្រិតបង្កើតគោលនយោបាយ។ <u>នៅលើឆាកនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ ក្នុងការបំបាត់ចោលនូវឯកជនភាវូនីយកម្មនៃ និងនិទ្ទណ្ឌភាពចំពោះឧក្រិដ្ឋកម្មយេនឌ័រ។ ជាលើកដំបូងបង្អស់ហើយ ដែលមានជំហាននានាក្នុងការទទួលស្គាល់ស្ត្រី ជាកម្មវត្ថុពេញលេញនៃសិទ្ធិមនុស្ស និងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនោះ"</u> (គូសបញ្ជាក់បន្ថែម)។

[៤៨] សំណើ កថាខណ្ឌ១៩។

[៤៩] *សូមមើល* លក្ខន្តិកៈ ICJ មាត្រា៣៨(១)(៣) ដែលថ្លែងថា តុលាការអាចពិចារណាយុត្តាធិការមុនៗរបស់ខ្លួនថាជា "មធ្យោបាយបន្ទាប់បន្សំសម្រាប់ការកំណត់វិធាននៃច្បាប់"។

[៥០] សំណើ កថាខណ្ឌ២១។

សម្រាប់ការអភិវឌ្ឍលើកិច្ចការផ្នែកសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ពិសេសក្នុងរង្វង់នៃសមាហរណកម្មយេនឌ័រ។ អានុភាពនៃការផ្លាស់ប្តូរជាគំរូនេះ ចាំបាច់ត្រូវពិចារណាឲ្យបានពេញលេញ យ៉ាងហោចណាស់ នៅពេលពិចារណាអំពីយុត្តាធិការ របស់ អ.វ.ត.ក នៅលើ និងទៅតាមសណ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែល (មិនដូចជា បទប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ)[៥១] មិនដែលធ្លាប់ត្រូវបានប្រមូលចងក្រងជាក្រមច្បាប់ឡើយ។

**ខ. ការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ដាច់ដោយឡែក" គឺជាការកាត់សេចក្តីលើបទល្មើសដែលលោក អៀង សារី ពុំអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងពុំអាចដឹងថាមានច្បាប់ចែង នៅចន្លោះឆ្នាំ ១៩៧៥-៧៩**

១៩. ក.ស.ព អះអាងថា លោក អៀង សារី គួរតែអាចយល់ដឹងជាមុនបានថា អំពើទាំងឡាយនៃបទរំលោភសេពសន្ថវៈ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥២]។ មានភាពខុសគ្នារវាង "ការហាមឃាត់" ពីការប្រព្រឹត្តបទរំលោភសេពសន្ថវៈក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង*ការចាត់ទុកការរំលោភសេពសន្ថវៈ* ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់។ បន្ថែមលើនេះទៀត បទឧក្រិដ្ឋមួយដែលពុំមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ ១៩៧៥-៧៩ អាចនឹងកំណត់បានយ៉ាងលំបាក ដោយលោក អៀង សារី ក្នុងគ្រានោះ។ សហមេធាវីការពារក្តីយោងលើអំណះអំណាងផ្សេងៗ ពាក់ព័ន្ធនឹងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង ក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[៥៣]។

---

[៥១] *Cf. id.*: "តាមពិត ច្បាប់អន្តរជាតិមិនមែនជាផលិតផលនៃលក្ខន្តិកៈសម្រាប់ជាមូលហេតុសាមញ្ញដែលថា នៅពុំទាន់មានអាជ្ញាធរពិភពលោកនៅឡើយ ដែលទទួលអំណាចក្នុងការអនុម័តលក្ខន្តិកៈនៃការអនុវត្តជាសកលដែរ"។ សហមេធាវីការពារក្តីស្នើថា ការអះអាងនេះត្រូវបានយល់ខុស។ អង្គនៃអង្គការសហប្រជាជាតិ ក៏ដូចជាគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមបានប្រកាសឲ្យប្រើប្រាស់នូវអនុសញ្ញា និងច្បាប់លក្ខន្តិកៈផ្សេងៗទៀត ដែលត្រូវបានប្រមូលចងក្រងជាក្រម ក្នុងចំណោមឯកសារផ្សេងៗទៀត ក្នុងនោះរួមមាន ច្បាប់ស្តីពីសង្គ្រាម និងបទប្រល័យពូជសាសន៍ ហើយដែលទទួលបាននូវឋានៈ ជាច្បាប់ទំនៀមទម្លាប់។

[៥២] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៣។

[៥៣] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៣០-៣៥។

២០. ក.ស.ព អះអាងថា នៅក្នុងវិសាលភាពដែលថាមានភាពមិនច្បាស់លាស់អំពីថាតើ ការរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឬយ៉ាងណា ហើយ "ដំណោះស្រាយលើភាពមិនច្បាស់លាស់នោះតាមរយៈការកំណត់សម្រេចតាមផ្លូវតុលាការ គឺអាចព្យាករណ៍ទុកជាមុនបាន"[៥៤]។ ទីមួយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិកើតចេញពីការអនុវត្តរបស់រដ្ឋ និងពី*សច្ចធារណ៍ធម្មានុរូប* (opinio juris)[៥៥]។ យ៉ាងច្រើន ការកំណត់ផ្លូវតុលាការគឺជាមធ្យោបាយបន្ទាប់បន្សំនានា សម្រាប់កំណត់វិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិប៉ុណ្ណោះ[៥៦]។ ទីពីរ ដើម្បីវាស់វែង ថាតើការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈអាចត្រូវបានព្យាករណ៍ទុកជាមុនបាន ក្នុងចន្លោះឆ្នាំ ១៩៧៥-៧៩ ឬយ៉ាងណានោះ គឺពុំទាមទារ ដូចការលើកឡើងរបស់ ក.ស.ព ឲ្យមានការវាយតម្លៃមួយ ថាតើវាមានលក្ខណៈអាចព្យាករណ៍ទុកជាមុនបានដែលវិធានច្បាប់ទំនៀមទម្លាប់អាចនឹងបកស្រាយបំភ្លឺនៅថ្ងៃអនាគតឡើយ[៥៧]។

២១. ក.ស.ព អះអាងថា "ចរិតលក្ខណៈជាក់ស្តែងយ៉ាងច្បាស់នៃអំពើនានាក្នុងបទរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩" គឺជាការមួយ "ដែលមិនអាចយល់បានទេដែលថា អ្នកមានសុភវិនិច្ឆ័យម្នាក់ បានជឿថា អំពើទាំងនេះមិនរំលោភទៅនឹងលក្ខខណ្ឌតម្រូវរបស់ច្បាប់ និងភាពសមស្របជាសកលទេ ដើម្បីធានាមិនឲ្យមានឧក្រិដ្ឋបនីយកម្មតាមរយៈមធ្យោបាយនៃបទល្មើសដាច់ពីគ្នាមួយជាដើម"[៥៨]។ តាមរយៈការផ្តល់យោបល់ទៅលើយុត្តិសាស្ត្រ

---

[៥៤] សំណើ កថាខណ្ឌ២៥។

[៥៥] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D97/14/5, ឧបសម្ព័ន្ធ"ក" ផ្នែក II"ច" សម្រាប់ការពិភាក្សាស៊ីជម្រៅអំពីការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[៥៦] *សូមមើល* លក្ខន្តិកៈ ICJ មាត្រា៣៨ (១)(៣)

[៥៧] អង្គបុរេជំនុំជម្រះបានរកឃើញថា ភាពដែលអាចព្យាករណ៍ទុកជាមុនបាននៃគោលការណ៍នីត្យានុកូលភាពតម្រូវថា ជនជាប់ចោទ "ត្រូវតែអាចដឹងថា មានច្បាប់ចែងបង្ហាញថា អំពើនោះគឺជាអំពើឧក្រិដ្ឋ នៅក្នុងអារម្មណ៍ដែលអាចដឹងជាទូទៅដោយមិនចាំបាច់សំអាងលើបទប្បញ្ញត្តិជាក់លាក់ណាមួយទេ"។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខD427/2/15 កថាខណ្ឌ១០៦។

[៥៨] សំណើ កថាខណ្ឌ២៥។

របស់តុលាការ *មិនអចិន្ត្រៃយ៍*នានា កញ្ញា Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងផ្តល់នូវសេចក្តីណែនាំយ៉ាងច្បាស់លាស់ទៅលើការអះអាងប្រភេទនេះ៖

> ភាពកម្រនៃការអនុវត្តរបស់រដ្ឋក្នុងការនាំផ្លូវតុលាការ *មិនអចិន្ត្រៃយ៍*នានា បានធានាថា អត្ថន័យនៃបទឧក្រិដ្ឋអន្តរជាតិ កំណត់ដោយតុលាការ *មិនអចិន្ត្រៃយ៍*នានា គឺសម្រាប់គោលបំណងនៃការបង្កើតច្បាប់ទៅថ្ងៃអនាគត (*de lege ferenda*)។ ដូចស្មេរម្នាក់បានកត់សម្គាល់ថា "ដូច្នេះ តុលាការត្រូវបាននាំផ្លូវ ហើយទំនងនឹងបន្តត្រូវគេនាំផ្លូវបន្ថែមទៀត ទៅលើការបំពានដោយអំពើជាក់លាក់មួយចំនួន ចំពោះភាពថ្លៃថ្នូររបស់មនុស្សជាតិ។ អំពើនោះកាន់តែសាហាវ តុលាការរឹតតែសន្មតថា អំពើនោះបំពានមិនត្រឹមតែលើគោលការណ៍សីលធម៌នៃមនុស្សជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពានលើនិយាមវិជ្ជមាននៃច្បាប់ទំនៀមទម្លាប់ទៀតផង"។ តថភាពនៃដំណើររៀបរយផ្នែកព្រហ្មទណ្ឌអន្តរជាតិដែលចេះតែវិវឌ្ឍ និងប្រែប្រួលនេះមានកើតឡើងទន្ទឹមគ្នា ដោយមិនចុះសម្រុងនឹងគ្នា ហើយពេលខ្លះ វាហាក់ដូចជាកម្រនឹងចុះសម្រុងនឹងសញ្ញាណនៃ *ការមិនមានបទល្មើស (បើគ្មានច្បាប់ចែង)* ដូចបានប្រមើលមើលទុកជាមុន ក្នុងរបាយការណ៍របស់អគ្គលេខាធិការ និងគុណតម្លៃ ជាមូលដ្ឋាននៃភាពអាចព្យាករណ៍បានជាមុន និងភាពច្បាស់លាស់នៃរបាយការណ៍នេះ[៥៩]។

## គ. ការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺមិនស្របគ្នាទៅនឹង "គោលបំណង" នៃគោលការណ៍នីត្យានុកូលភាព

២២. ក.ស.ព អះអាងថា "សំណួរពាក់ព័ន្ធនៅ អ.វ.ត.ក គឺថាតើ *ការប្រព្រឹត្តដែលឈានដល់ការរំលោភសេពសន្ថវៈ* អាចត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ តាមបែបដូចជាត្រូវបានព្យាករណ៍ទុកជាមុនបានថា ជនជាប់ចោទអាចនឹងត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយមានមូលដ្ឋាននៅលើការប្រព្រឹត្តនោះដែរ ឬទេ។ បើនិយាយឲ្យខ្លីបញ្ហា គឺនៅលើអង្គសេចក្តី មិនមែននៅលើការដាក់ឈ្មោះនោះទេ"[៦០]។ សំណួរលើក

---

[៥៩] Susan Lamb, គោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង (*Nullum crimen*) គោលការណ៍គ្មានការផ្តន្ទាទោសណាមួយ ដែលគ្មានច្បាប់ចែងនោះឡើយ (*nulla poena sine lege*) នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក្នុង Cassese, Gaeta និង Jones (eds.), នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ: A COMMENTARY: VOLUME 1 (Oxford 2002) 733-66 នៅទំព័រ 746។

[៦០] សំណើ កថាខណ្ឌ២៧។

ឡើងក្នុងការអះអាងនេះមានលក្ខណៈមិនស្របគ្នានឹងសំណូមពរ ដែលសហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង "កំណត់បទចោទសាជាថ្មី លើអង្គហេតុនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានជាក់ទាក់ទងទៅនឹងការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសើរជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[៦១]។ តាមរយៈការអះអាងទីមួយនេះ ក.ស.ព ហាក់ដូចជាទទួលស្គាល់ថា បទរំលោភសេពសន្ថវៈ ពុំមែនត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយក្នុងចន្លោះឆ្នាំ១៩៧៥-៧៩។ សំណូមពរដែលបានស្នើសុំគឺសំអាងទៅលើការសន្មតជាមុនថាវាជាបទរំលោភសេពសន្ថវៈ។

២៣. ការអះអាងរបស់ ក.ស.ព ដែលថា ការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ ផ្តល់នូវភាពច្បាស់លាស់កើនឡើងចំពោះលោក អៀង សារី និងងាយយល់ជាងចំពោះសាធារណជនទូទៅ[៦២]។ សំណួរពាក់ព័ន្ធចំពោះអង្គជំនុំជម្រះសាលាដំបូង ហើយដែលស្របគ្នាទៅនឹងគោលបំណងនៃគោលការណ៍នីត្យានុកូលភាព រួមមាន៖ **ក.** ថាតើបទរំលោភសេពសន្ថវៈដែលត្រូវបានផ្តន្ទាទោស ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឬទេ និង **ខ.** ថាតើការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈដែលត្រូវបានផ្តន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគួរតែលោកអៀង សារី អាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និងអាចដឹងថាមានច្បាប់ចែង ដែរឬទេ[៦៣]។

**ឃ. សំណួរថាតើអង្គហេតុនានាក្នុងដីកាដំណោះស្រាយផ្តល់ជាមូលដ្ឋានមួយគ្រប់គ្រាន់ដែរឬទេ ក្នុងការបង្ហាញថា បទរំលោភសេពសន្ថវៈដែលបានកើតឡើង ពុំពាក់ព័ន្ធនឹងការវិភាគនេះ**

២៤. ក.ស.ព អះអាងថា "ដីកាដំណោះស្រាយបានកំណត់អំពីអង្គហេតុនានាដែលថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានកើត

---

[៦១] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣៣។

[៦២] ដូចជើងទំព័រខាងលើ កថាខណ្ឌ២៨។

[៦៣] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារលេខ D97/17/6 កថាខណ្ឌ៤៣។

ឡើងក្នុងរយៈកាលដែលពាក់ព័ន្ធ[៦៤]។ ក្នុងកថាខណ្ឌទាំងបីខាងក្រោម ក.ស.ព លើកឡើងដដែលៗនូវការចោទប្រកាន់ ដូចមានចែងក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងការចោទអំពីការចេញបទបញ្ជាអំពី "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[៦៥] ការចោទអំពីបទរំលោភសេពសន្ថវៈ ក្នុងបរិបទនៃចំណង"អាពាហ៍ពិពាហ៍ដោយបង្ខំ"[៦៦] និងការចោទអំពីបទរំលោភសេពសន្ថវៈ ដែលស្ថិតខាងក្រៅបរិបទនៃ "អាពាហ៍ពិពាហ៍ដោយបង្ខំ" ដែលសហព្រះរាជអាជ្ញាសន្និដ្ឋានថា ឧក្រិដ្ឋកម្មបែបនេះ គឺជា"ផលវិបាកដែលគេអាចទាយទុកជាមុនបានអំពីសហឧក្រិដ្ឋកម្មរួម"[៦៧] សហមេធាវីការពារក្ដីស្នើថាអង្គជំនុំជម្រះសាលាដំបូងមិនបាច់យកចិត្តទុកដាក់នឹងកថាខណ្ឌទាំងបួននេះឡើយ[៦៨]។ ទីមួយ (ដូចបានបង្ហាញខាងលើ) អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការក្នុងការពិចារណា ថាតើអង្គហេតុដែលមានក្នុងរឿងក្ដីនេះប៉ូកបញ្ចូលនឹងបទរំលោភសេពសន្ថវៈដែលត្រូវផ្ដន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬយ៉ាងណានោះ។ ទីពីរ បើទោះជាអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខ្លួនពិតជាមានយុត្តាធិការនេះក៏ដោយ ការពិចារណាថាតើ "អង្គហេតុក្នុងដីកាដំណោះស្រាយផ្ដល់នូវមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ការរកឃើញថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃបទរំលោភសេពសន្ថវៈបានកើតឡើង" អាចគ្រាន់តែកើតឡើងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានស្ដាប់ភស្តុតាងនានាពាក់ព័ន្ធនឹងបញ្ហានេះឬយ៉ាងណា ហើយមានសមត្ថភាពក្នុងគូសបញ្ជាក់អំពីការពិតនៃការចោទប្រកាន់ទាំងនេះ។ នេះជាសំណួរដែលនឹងយកមកពិចារណាបានតែនៅពេលជំនុំជម្រះប៉ុណ្ណោះ។

## IV. សេចក្ដីសន្និដ្ឋាន និងសំណូមពរ

---

[៦៤] សំណើ កថាខណ្ឌ២៩។

[៦៥] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣០។

[៦៦] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣១។

[៦៧] ដូចជើងទំព័រខាងលើ កថាខណ្ឌ៣២។

[៦៨] សារណារបស់សហមេធាវីក្នុងចម្លើយតបនេះធ្វើឡើង ដោយមិនប៉ះពាល់នឹងគោលជំហររបស់ខ្លួនដែលថា ថាតើបទឧក្រិដ្ឋមួយគឺជា "ផលប៉ះពាល់ដែលអាចព្យាករណ៍ទុកជាមុនបាននៃសហឧក្រិដ្ឋកម្មរួម" ឬយ៉ាងណានោះ គឺមិនពាក់ព័ន្ធនឹងការវាយតម្លៃថាតើវាត្រូវបានជឿជាក់ថាជាការទទួលខុសត្រូវរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួមមួយនៅ អ.វ.ត.ក ឡើយ។ *សូមមើល* សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្ម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១០ ឯកសារលេខ D97/17/6។

២៥. បញ្ហានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺវិធាន៨៩(១) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងអញ្ញត្រកម្ម ដែលជាបញ្ហាផ្នែកច្បាប់សុទ្ធសាធ។ អង្គបុរេជំនុំជម្រះបានដោះស្រាយរាល់បញ្ហា ទាក់ទិននឹងថាតើ បទរំលោភសេពសន្ថវៈ ដែលត្រូវផ្តន្ទាទោស ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានក្នុងច្បាប់ ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ដែរឬយ៉ាងណានោះ។ អង្គបុរេជំនុំជម្រះបាន សម្រេចថា វាពុំមែនឡើយ ដូច្នេះហើយមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានឡើយ។ ក.ស.ព មិនអើពើនឹងវិធាន៨៩(១) នៃវិធានផ្ទៃក្នុងទេ ហើយក៏មិនបានដាក់អញ្ញត្រកម្មអ្វីដែរ។ ឥឡូវនេះ ខ្លួន មិនអាចសំណូមពរ ជាទម្រង់នៃការកំណត់បទចោទសាជាថ្មីនៃអង្គហេតុ ជាមធ្យោបាយក្នុង ការចៀសឲ្យផុតពីវិធាននេះ ឬព្យាបាលកង្វះខាតនៃវីរិយភាពទាន់ពេលវេលារបស់ខ្លួនបានឡើយ។ បើទោះជាអង្គជំនុំជម្រះសាលាដំបូងគួរសម្រេចពិចារណាទៅលើសំណើនេះ អនុលោមតាមវិធាន ៩៨នៃវិធានផ្ទៃក្នុងក្តី សំណើនេះគួរត្រូវបានបដិសេធចោលដោយសារគ្មានអង្គសេចក្តី។

**អាស្រ័យហេតុនេះ** ដោយយោងទៅតាមហេតុផលដូចបានរៀបរាប់ជូនខាងលើ សហមេធាវីការពារក្តី សូមលើកសំណើទៅអង្គជំនុំជម្រះសាលាដំបូងគួរធ្វើការ៖

ក. **បដិសេធ**ចោលសំណើនេះ ដោយហេតុពុំបានដាក់ក្នុងរយៈពេលកំណត់ ឬ បើមិនដូច្នោះទេ

ខ. **សម្រេច**បើកសវនាការដេញដោលដោយផ្ទាល់មាត់ និងជាសាធារណៈ ព្រមទាំង

គ. **ច្រានចោល**សំណើនេះលើអង្គសេចក្តី។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកចម្លើយតបនេះដោយក្តីគោរព។

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**